# បទបង្ហាញ
# ស្ដីពី

# វឌ្ឍនភាពការងារឆ្នាំ២០២៥
# និងទិសដៅការងារបន្ត ឆ្នាំ២០២៦
# របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦





# មាតិកា

១. អាណត្តិ ចក្ខុវិស័យ បេសកកម្ម តួនាទីភារកិច្ច និងគុណតម្លៃ

២. រចនាសម្ព័ន្ធ និងស្ថានភាពមន្ត្រីរាជការ

៣. វឌ្ឍនភាពការងាររបស់អាជ្ញាធរទន្លេសាប

៤. បញ្ហាប្រឈម

៥. ដំណោះស្រាយ

៦. ទិសដៅការងារបន្ត

# ១. អាណត្តិ ចក្ខុវិស័យ បេសកកម្ម តួនាទីភារកិច្ច និងគុណតម្លៃ

**អាណត្តិ**

“សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប”

**ចក្ខុវិស័យ**

អាជ្ញាធរទន្លេសាប ជាស្ថាប័នប្រកបដោយឧត្តមភាពការងារ ក្នុងការសម្របសម្រួល ដល់ការគ្រប់គ្រងធនធានទឹក ធនធានធម្មជាតិ និងបរិស្ថានតំបន់ទន្លេសាប។

**បេសកកម្ម**

សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយចីរភាព។

**គុណតម្លៃ**

រក្សាបាននូវសុច្ចរិតភាព ការអនុវត្តសមធម៌ ការឆ្លើយតប និងទិសដៅលទ្ធផល។

# តួនាទីភារកិច្ច

1. សិក្សាស្រាវជ្រាវ វិភាគ និងគ្រប់គ្រងព័ត៌មានទិន្នន័យ
2. សហការជាមួយក្រសួងស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងគម្រោងផ្សេងៗ
3. សម្របសម្រួលរាល់សកម្មភាព ដែលបាន និងកំពុងអនុវត្ត គ្រោងនឹងអនុវត្ត របស់ក្រសួងស្ថាប័នអាជ្ញាធរដែនដី អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា ដែលមាននៅក្នុងតំបន់ទន្លេសាប ដើម្បីឱ្យមានភាពរលូន និងប្រកបដោយប្រសិទ្ធភាព
4. តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងនានា ដើម្បីជំរុញឱ្យប្រតិបត្តិករពាក់ព័ន្ធអនុវត្តស្របតាមយុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាល
5. ធ្វើជាតំណាងរាជរដ្ឋាភិបាល ក្នុងសកម្មភាពការងាររួមមានកិច្ចប្រជុំការចចារ និងការដោះស្រាយរាល់បញ្ហា ដែលអាចកើតមានជាយថាហេតុ

# តួនាទីភារកិច្ច ( ត )

6. ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ កិច្ចសន្យាទាំងឡាយ ក្រោយពីមានការឯកភាពពីរាជរដ្ឋាភិបាល

7. ជាសមភាគីជាមួយគ្រប់ដៃគូអភិវឌ្ឍទាំងអស់ក្នុងការរួមគ្នាពិចារណា ដើម្បីកំណត់សកម្មភាពដែលត្រូវអនុវត្ត

8. ប្រមូល វិភាគ និងធ្វើបច្ចុប្បន្នភាពព័ត៌មានទិន្នន័យ ដើម្បីផ្សព្វផ្សាយ និងចែករំលែកអ្នកពាក់ព័ន្ធ

9. អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង ដល់អ្នកពាក់ព័ន្ធ

10. រាយការណ៍ជូនរាជរដ្ឋាភិបាលអំពីសកម្មភាពការងារសំខាន់ៗ

11. អនុវត្តតាមបទបញ្ជា និងភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

# ២. រចនាសម្ព័ន្ធ និងស្ថានភាពមន្ត្រីរាជការ

## ✓ រចនាសម្ព័ន្ធ






# ✓ ស្ថានភាពមន្ត្រីរាជការ




| ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ | | |
|---|---|---|
| - ប្រធាន អ.ទ.ស | ១ រូប | |
| - អនុប្រធាន អ.ទ.ស | ៣ រូប | |
| - អគ្គលេខាធិការ | ១ រូប | |
| - អគ្គលេខាធិការរង | ២ រូប | |
| - ទីប្រឹក្សា | ២ រូប | (ស្រី ១ រូប) |
| - ប្រធាននាយកដ្ឋាន | ៤ រូប | |
| - អនុប្រធាននាយកដ្ឋាន | ១០ រូប | (ស្រី ២ រូប) |
| - ប្រធានការិយាល័យ | ១៣ រូប | |
| - អនុប្រធានការិយាល័យ | ២៨ រូប | (ស្រី ៩ រូប) |
| - មន្ត្រីគ្រប់គ្រងរដ្ឋបាល | ៥ រូប | (ស្រី ២ រូប) |
| - មន្ត្រីបច្ចេកទេស | ១ រូប | |
| - មន្ត្រីជាប់កិច្ចសន្យា | ២៩ រូប | (ស្រី ៦ រូប) |
| **សរុបរួម ៖** | **៩៩ រូប** | **(ស្រី ២០រូប)** |







# ៣. វឌ្ឍនភាពការងាររបស់អាជ្ញាធរទន្លេសាបឆ្នាំ២០២៥

# ៣.១ ការគ្រប់គ្រងរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

## ក. ការងាររដ្ឋបាល




- រៀបចំលិខិតរដ្ឋបាល លិខិតចេញ-លិខិតចូល ទទួលមុខការ និងរក្សាឯកសារ
- បូកសរុបរបាយការណ៍សកម្មភាពការងារថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន អ.ទ.ស ប្រចាំខែ ឆមាស និងប្រចាំឆ្នាំ
- បានសហការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានា
- បានសម្របសម្រួលកិច្ចការរដ្ឋបាលជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ អ.ទ.ស
- គ្រប់គ្រង ត្រួតពិនិត្យសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យជាប្រចាំ
- រៀបចំផែនការផ្គត់ផ្គង់ គ្រប់គ្រង ថែទាំសម្ភារៈ ឧបករណ៍ និងមធ្យោបាយ។

# ខ. ការងារគ្រប់គ្រងបុគ្គលិក និងបណ្ដុះបណ្ដាល

## ❖ ការងារគ្រប់គ្រងបុគ្គលិក

- បានរៀបចំបូកសរុបបញ្ជីវត្តមានប្រចាំខែ និងបានបូកសរុបស្ថិតិ មន្ត្រីរាជការ អ.ទ.ស
- បានរៀបចំបូកសរុបបញ្ជីវត្តមានប្រចាំខែរបស់អគ្គលេខាធិការដ្ឋាន អ.ទ.ស ផ្ញើជូនក្រសួងធនធានទឹក និងឧតុនិយម និងក្រសួង មុខងារសាធារណៈ
- បានរៀបសំណុំឯកសារ ស្ដីពីការបន្តប្រើប្រាស់ និងជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា សម្រាប់ អ.ទ.ស ចំនួន ២៩នាក់ ក្នុងឆ្នាំ២០២៥
- បានទទួលរៀបចំដំឡើងថ្នាក់តាមវេនអតីតភាពការងាររបស់មន្ត្រីរាជការ អ.ទ.ស ជូនទៅក្រសួងមុខងារសារធារណៈ ចំនួន ៣៩នាក់
- បានរៀបចំឯកសារពាក់ព័ន្ធ ដើម្បីធ្វើប្រកាសផ្ទេរឈ្មោះមន្ត្រីរាជការ អ.ទ.ស ចំនួន ០១រូប ដែលបានផ្ទេរទីកន្លែងការងារទៅមន្ទីរធនធានទឹក និងឧតុនិយមខេត្តបន្ទាយមានជ័យ
- កំពុងធ្វើបច្ចុប្បន្នភាពបញ្ចូលទិន្នន័យប្រវត្តិរូបមន្ត្រីរាជការ របស់អាជ្ញាធរទន្លេសាប ក្នុងប្រព័ន្ធ HR MIS តាមការណែនាំរបស់ក្រសួងមុខងារសារធារណៈ
- បានរៀបចំឯកសារស្នើសុំ និងបានបោះពុម្ពប័ណ្ណសំគាល់ខ្លួនមន្ត្រីរាជការ ជូនថ្នាក់ដឹកនាំ និងមន្ត្រី អ.ទ.ស
- បានរៀបចំ និងសហការជាមួយក្រសួង ធ.ទ.ឧ ដើម្បីធ្វើបច្ចុប្បន្នភាពប័ណ្ណសមាជិក ប.ស.ស ជូនថ្នាក់ដឹកនាំ និងមន្ត្រី អ.ទ.ស
- រៀបចំលិខិតបេសកកម្មចេញក្នុងប្រទេសមានចំនួន ២២២លេខ។

# ❖ ការងារបណ្តុះបណ្តាល




- វគ្គបណ្តុះបណ្តាលស្តីពី វិជ្ជាជីវៈលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាម FMIS សម្រាប់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញថ្នាក់កណ្តាលបន្ថែមថ្មី នៃក្រសួង-ស្ថាប័នចំនួន៦ និងអ្នកប្រើប្រាស់ថ្មីទៅតាមការដ្ឋាន
- ចូលរួមសង្កេតការពីដំណើរជំរឿនមន្ត្រីរាជការនៅក្រសួងមុខងារសាធារណៈ
- បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលបច្ចេកទេស ស្តីពីការធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌគាំទ្រការសម្រេចចិត្ត ( Decision Support Framework-DSF ) នៅខេត្តកំពង់ឆ្នាំង
- មន្ត្រីបច្ចេកទេសវ័យក្មេង អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប រួមជាមួយនិស្សិតកម្មសិក្សាមកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ទទួលបានការបណ្តុះបណ្តាលចំណេះដឹងពង្រឹងសមត្ថភាពបន្ថែម ដោយអ្នកជំនាញម៉ូឌែល លោកបណ្ឌិត លី ស្ទីវិន អំពីការប្រើប្រាស់ម៉ូឌែល Rainfall-Runoff-Inundation ( RRI-Model )
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការបន្សាំ នឹងប្រព័ន្ធអេកូឡូស៊ីទៅក្នុងគោលនយោបាយដើម្បីពង្រឹងសមភាពយេនឌ័រនៅក្នុងមហាអនុតំបន់មេគង្គ" Ecosystem-Based Adaptation into policy to Strengthen Gender Equality in the Greater Mekong Subregion " នៅសណ្ឋាគារ Crown Plaza នៅទីក្រុងវៀងចន្ទ ប្រទេសឡាវ

## ❖ ការងារបណ្តុះបណ្តាល (ត)

- វគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងទឹកជំនន់ ការព្រមានជាមុន ការព្យាករអាកាសធាតុ និងការតាមដានរបបជលសាស្ត្រ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ នៅសាធារណរដ្ឋប្រជាមានិតចិន
- សិក្ខាសាលាថ្នាក់តំបន់ស្តីពី ផ្ទាំងបង្ហាញ (Dashboard) ការតាមដានភាពសម្បូរត្រី និងភាពចម្រុះប្រភេទត្រី របស់គណៈកម្មការទន្លេមេគង្គ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម។










# គ. ការងារគ្រប់គ្រងហិរញ្ញវត្ថុ

ការអនុវត្តកញ្ចប់ថវិកាអាជ្ញាធរទន្លេសាបឆ្នាំ២០២៥ ក្នុងរង្វង់
៤ ៣០០ លានរៀល




- បានអនុវត្តនីតិវិធីកិច្ចលទ្ធកម្មចប់ជាស្ថាពរចំនួន ១០គម្រោង (ទំនិញ៨ សំណង់១ សេវាកម្ម១)
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់នីតិវិធីអនុវត្តកិច្ចលទ្ធកម្មសាធារណៈ (ព្រាងអនុក្រឹត្យ ប្រកាស...)
- បានរៀបចំរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស របាយការណ៍ប៉ាន់ស្មានប្រចាំឆ្នាំ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៦ ដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុម័ត
- បានរៀបចំផែនការថវិកាឆ្នាំ និងវិភាជន៍តាមមុខសញ្ញាចំណាយនីមួយៗ
- បានផ្គត់ផ្គង់សម្ភារបរិក្ខា ព័ត៌មានវិទ្យា មិនមែនព័ត៌មានវិទ្យា សង្ហារឹម ការិយាល័យ ប្រេងឥន្ធនៈ .....
- បានធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងតារាងប្រៀបធៀបសម្ភារ (កើន ថយ) ប្រចាំឆ្នាំ ២០២៥
- បានរៀបចំឯកសារទូទាត់ចំណាយបន្ទាន់ ប្រចាំក្នុងអង្គភាព (ទឹក អាហារសម្រន់ កាហ្វេ និងជួសជុលថែទាំផ្សេងៗ...)
- បានទំនាក់ទំនងជាប្រចាំជាមួយក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិនៃកម្ពុជា ដើម្បីដំណើរការឯកសារ។

# គ. ការងារគ្រប់គ្រងហិរញ្ញវត្ថុ (ត)

- បានរៀបចំឯកសារទូទាត់ថ្លៃប្រើប្រាស់សេវាអ៊ីនធើណេត អគ្គិសនី ទឹក ឆ្នាំ២០២៥
- បានរៀបចំឯកសារទូទាត់ (សក្ខីប័ត្រចំណាយ) រដ្ឋទេយ្យបុរេប្រទានចំនួន ៤ជុំបង្វិល
- បានរៀបចំឯកសារទូទាត់ប្រាក់បេសកកម្មចំនួន ៦លើក និងរៀបចំប្រាក់បេសកកម្មបង្វែរត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីរាជការ អ.ទ.ស តាមប្រព័ន្ធធនាគារ
- បានរៀបចំរបាយការណ៍ និងកិច្ចបញ្ជីការគណនេយ្យ ជូនអគ្គនាយកដ្ឋានរតនាគារជាតិ (ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ)
- បានសហការ រៀបចំកសាងឯកសារគម្រោងថវិកាឆ្នាំ២០២៦ (ទាំងកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំ)
- បានរៀបចំរបាយការណ៍ចំណូល-ចំណាយ (ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ)
- បានអនុវត្តការងារចាំបាច់ផ្សេងៗ មួយចំនួនទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

# ៣.២ ការងារផែនការ និងសហប្រតិបត្តិការ

## ក. ការងារកសាងផែនការ

- បានកសាងនូវផែនការយុទ្ធសាស្ត្រសម្រាប់អាជ្ញាធរទន្លេសាប បានចំនួន៣ លើក ៖
  - ✓ ផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ២០១៦-២០២០
  - ✓ ផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ២០២១-២០២៥
  - ✓ ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ ២០២១-២០២៥ ទៅជាផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨
- បានកសាងផែនការសកម្មភាពការងារប្រចាំឆ្នាំ បានចំនួន១៣ លើក (ឆ្នាំ ២០១៤-២០២៦)






កិច្ចប្រជុំ
វាយតម្លៃការអនុវត្តសកម្មភាពការងារប្រចាំឆ្នាំ ២០២៣
ពិនិត្យ វឌ្ឍនភាពការងាររបស់អាជ្ញាធរទន្លេសាប ឆ្នាំ ២០២៣
និងលើកទិសដៅបន្តអនុវត្តឆ្នាំ ២០២៤




KINGDOM OF CAMBODIA
NATION RELIGION KING
TONLE SAP AUTHORITY STRATEGIC PLAN
2024-2028
COORDINATE THE MANAGEMENT, CONSERVATION AND DEVELOPMENT
OF TONLE SAP AREAS
January 2024


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប
២០២៤-២០២៨
សិក្សាស្រាវជ្រាវ និងសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍
តំបន់បឹងទន្លេសាបប្រកបដោយចីរភាព

# ខ. ការងារសហប្រតិបត្តិការ

## ➢ កិច្ចប្រជុំ

❖ ឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ដឹកនាំ កិច្ចប្រជុំផ្សព្វផ្សាយពីលទ្ធផលការងាររបស់អាជ្ញាធរទន្លេសាប និងទិសដៅអនុវត្តបន្តឆ្នាំ២០២៥។










## ➢ ការចុះទស្សនកិច្ចសិក្សា

❖ ឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប បានអញ្ជើញដឹកនាំ គណៈប្រតិភូសមាជិកអាជ្ញាធរទន្លេសាប ដែលជាតំណាងក្រសួង ស្ថាប័ន និងអាជ្ញាធរខេត្តពាក់ព័ន្ធ ធ្វើដំណើរទស្សនកិច្ចសិក្សាស្វែងយល់ពីសក្តានុពលតំបន់បឹងទន្លេសាប(បឹងពារាំង) ស្ថិតក្នុងភូមិសាស្ត្រសង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។







## ➢ ការជួបពិភាក្សាការងារ

❖ ឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប ជួបប្រជុំជាមួយ ឯកឧត្តម **Li Guoying** រដ្ឋមន្ត្រីក្រសួងធនធានទឹក នៃសាធារណរដ្ឋប្រជាមានិតចិន ពិភាក្សាការងារនៅរាជធានីភ្នំពេញ។






## ➢ ការចុះទស្សនកិច្ចសិក្សា

❖ ឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប ជួបប្រជុំជាមួយ ឯកឧត្តម **Li Guoying** រដ្ឋមន្ត្រីក្រសួងធនធានទឹក នៃសាធារណរដ្ឋប្រជាមានិតចិន និងបានដឹកនាំគណៈប្រតិភូចុះទស្សនកិច្ចស្វែងយល់អំពីតំបន់បឹងទន្លេសាប ស្ថិតក្នុងភូមិសាស្រ្ត ខេត្តសៀមរាប។






## ➢ កិច្ចប្រជុំ

❖ ឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប បានអញ្ជើញដឹកនាំកិច្ចប្រជុំកិច្ចប្រជុំស្តីពីវឌ្ឍនភាពការងារឆ្នាំ២០២៥ និងទិសដៅអនុវត្តការងារបន្តឆ្នាំ២០២៦ របស់អាជ្ញាធរទន្លេសាប នៅសាលប្រជុំរំដួលនៃទីស្តីការក្រសួងធនធានទឹក និងឧតុនិយម។










## ➢ ការចុះទស្សនកិច្ចសិក្សា

- ឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប អញ្ជើញដឹកនាំគណៈប្រតិភូអាជ្ញាធរទន្លេសាប ចុះទស្សនកិច្ចស្វែងយល់អំពីផលនេសាទ តាមរយៈការធ្វើអាជីវកម្មឡូត៍ដាយ នៅតាមដងទន្លេសាប នារដូវបើកនេសាទ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងខេត្តកណ្ដាល។










## ➢ ពិធីចុះអនុស្សរណៈយោគយល់ ( MoU )

❖ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមរដ្ឋមន្ត្រី **ថោ ជេដ្ឋា** ប្រធានអាជ្ញាធរទន្លេសាប ឯកឧត្តម **ហ៊ើល តូនី** អនុប្រធានក្តាប់រួមអាជ្ញាធរទន្លេសាប រួមជាមួយ ឯកឧត្តម **សរ គឹមសាន្ត** អគ្គលេខាធិការអាជ្ញាធរទន្លេសាប ដឹកនាំមន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប ជួបពិភាក្សាការងារជាមួយគណៈប្រតិភូមេគង្គ-ឡានឆាង ដែលដឹកនាំដោយឯកឧត្តម Dr. Zhou Zhiwei អគ្គលេខាធិការ មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការធនធានទឹកឡានឆាង-មេគង្គ (Lancang-Mekong Water Resources Cooperation Center-LMC)។










## ➢ កិច្ចប្រជុំ

❖ កិច្ចសហប្រតិបត្តិការយុទ្ធសាស្ត្រ និងភាពធន់នឹងអាកាសធាតុ ជាមួយធនាគារពិភពលោក (WB), DFAT និង AWP ដើម្បីកសាងកិច្ចសហការលើសន្តិសុខទឹក និងភាពធន់នៅបឹងទន្លេសាប សម្រាប់កម្មវិធីឆ្នាំ ២០២៤-២០២៦។



## ➢ កិច្ចប្រជុំ

❖ ឯកឧត្តមរដ្ឋមន្ត្រី **ថោ ជេដ្ឋា** ប្រធានអាជ្ញាធរទន្លេសាប រួមជាមួយ លោកស្រី Bridget Collier អនុប្រធានបេសកកម្មនៃស្ថានទូតអូស្ត្រាលី និងលោកស្រី Maria Angelica Sotomayor ប្រធានគ្រប់គ្រងការអនុវត្តទឹកប្រចាំអាស៊ីប៉ាស៊ីហ្វិច នៃធនាគារពិភពលោក បានអញ្ជើញជាអធិបតីភាពបើកសិក្ខាសាលា ស្ដីពីការចាប់ផ្ដើមសិក្សា និងវិភាគសន្តិសុខទឹកក្នុងអាងទន្លេសាប ក្នុងការអនុវត្តកម្មវិធីវាយតម្លៃសន្តិសុខទឹក និងភាពធន់នៃបឹងទន្លេសាប សម្រាប់ឆ្នាំ ២០២៤-២០២៦។










## ➢ កិច្ចប្រជុំ

❖ កិច្ចប្រជុំពិគ្រោះយោបល់ស្ដីពីការវិភាគសន្តិសុខទឹកនៅអាងទន្លេសាបក្នុងភូមិសាស្ត្រខេត្តទាំង៦ ជុំវិញបឹងទន្លេសាប និងខេត្តចំនួន៣ ដែលជាផ្ទៃរងទឹកភ្លៀងរបស់បឹងទន្លេសាប។











## ➢ ការចុះទស្សនកិច្ចសិក្សា

❖ បន្ទាប់ពីបញ្ចប់កិច្ចប្រជុំ ក្រុមការងារអាជ្ញាធរទន្លេសាប និងតំណាងធនាគារពិភពលោក(WB) ISEM DFAT AWP ក៏បានចុះទស្សនកិច្ចសិក្សាផ្ទាល់ដល់ទីតាំងជាក់ស្តែងនៅតាមទីតាំងសំខាន់ៗ ក្នុងខេត្តទាំង៦ ជុំវិញបឹងទន្លេសាប។











## ➢ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍

❖ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន (AFD)










❖ សហការអនុវត្តគម្រោងតាមដានផលចាប់នៅខេត្តជុំវិញបឹងទន្លេសាប គាំទ្រថវិកាដោយ MRC តាមរយៈ CNMC









## ➢ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ (ត)

❖ សហការអនុវត្តគម្រោងសិក្សាជាគម្រូបច្ចេកវិទ្យាសង្កេត និងបញ្ជូនទិន្នន័យជលសាស្ត្រ សម្រាប់អាងទន្លេសាបកម្ពុជា ចំនួន ១១ស្ថានីយ៍ គាំទ្រថវិកាដោយគម្រោងឡានឆាង- មេគង្គ។










## ➢ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ (ត)

- ✓ សហការជាមួយសាកលវិទ្យាល័យ Aalto University និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សិក្សារួមគ្នា លើប្រធានបទ " ស្វែងរកអនាគតរបស់ទន្លេសាប "

- ✓ សហការគម្រោងបង្កើតវេទិកាអភិរក្សបរិស្ថានបឹងទន្លេសាប (Establishment of Environmental Conservation Platform of Tonle Sap Lake) ជាមួយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា គាំទ្រដោយ វិទ្យាស្ថាន TOKYO Institute of Technology នៃភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)

- ✓ សហការអនុវត្តគម្រោងការវិភាគតម្រូវការទឹកក្នុងអាងស្តុកទឹកស្ទឹងពោធិ៍សាត់ (Water Demand analysis within the Pursat River Catchment) ជាមួយក្រសួងធនធានទឹក និងឧតុនិយម ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) និងសមាគមន៍ការពារវប្បធម៌ និងបរិស្ថាន (CEPA)

# ៣.៣ ការងារសិក្សាស្រាវជ្រាវ និងប្រមូលចងក្រងព័ត៌មាន ទិន្នន័យ និងផ្សព្វផ្សាយ

## ការងារសិក្សាស្រាវជ្រាវ



ផ្នែកធនធានធម្មជាតិ និងជីវចម្រុះ











# ការចុះសិក្សាស្រាវជ្រាវ



ផ្នែកអាជីវកម្ម និងអភិរក្ស











# ការងារសិក្សាស្រាវជ្រាវ

## ផ្នែកគុណភាពទឹក

















# ការងារសិក្សាស្រាវជ្រាវ



ការងារចុះធ្វើបច្ចុប្បន្នភាព
ប្រជាសាស្ត្រ សេដ្ឋកិច្ចសង្គម
តំបន់បឹងទន្លេសាប










# ការងារប្រមូលចងក្រងព័ត៌មាន ទិន្នន័យ

សកម្មភាពចុះសិក្សាស្រាវជ្រាវឆ្នាំ២០២៥ អាជ្ញាធរទន្លេសាប បានយកចិត្តទុកដាក់ក្នុងការវិភាគចងក្រងនូវរាល់ព័ត៌មានទិន្នន័យពាក់ព័ន្ធ រួមមាន ៖

(១). សៀវភៅការសិក្សាពីប្រភេទសត្វស្លាបនៅតំបន់ទន្លេសាប

(២). សៀវភៅការសិក្សាពីប្រភេទព្រៃលិចទឹកតំបន់ទន្លេសាប

(៣). សៀវភៅកម្រងរូបភាពត្រីទន្លេមេគង្គ និងត្រីតំបន់នានាដែលពាក់ព័ន្ធតំបន់បឹងទន្លេសាប

(៤). សៀវភៅការសិក្សាតាមដានអាជីវកម្មឡូត៍ជាយរដូវនេសាទឆ្នាំ ២០២៤-២០២៥











# ការងារផ្សព្វផ្សាយព័ត៌មាន ទិន្នន័យ



- សហការជាមួយក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្សព្វផ្សាយពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

- ផ្សព្វផ្សាយពីសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រីអាជ្ញាធរទន្លេសាប តាមរយៈបណ្តាញសង្គម(Website, Facebook, Telegram Channel, Youtube Channel,Twitter)..។







# ៣.៤ ការងារចំពោះមុខ

## ក. ការងារចុះពិនិត្យស្ថានភាពទឹកជំនន់តាមបណ្តាស្ទឹងសំខាន់ៗ ជុំវិញបឹងទន្លេសាប

ឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប បានដឹកនាំក្រុមការងារអញ្ជើញចុះពិនិត្យស្ថានភាពជាក់ស្តែងជំនន់ទឹកភ្លៀងក្នុងភូមិសាស្ត្រខេត្តកំពង់ធំ និងខេត្តសៀមរាប។







# ក. ការចារចុះពិនិត្យស្ថានភាពទឹកជំនន់តាមបណ្ដាស្ទឹងសំខាន់ៗ ជុំវិញបឹងទន្លេសាប(ត)

ដោយទទួលបានការណែនាំចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរទន្លេសាប ថ្នាក់ដឹកនាំ និងក្រុមការងារ មន្ត្រីបច្ចេកទេស សហការជាមួយនឹងមន្ទីរធនធានទឹក និងឧតុនិយម ខេត្តទាំង៦ ចុះពិនិត្យស្ថានភាពទឹកជំនន់តាមបណ្ដាស្ទឹងសំខាន់ៗជុំវិញបឹងទន្លេសាប។



*សកម្មភាពចុះពិនិត្យស្ថានភាពទឹកជំនន់តាមបណ្ដាស្ទឹងសំខាន់ៗ ជុំវិញបឹងទន្លេសាប (មុខព្រួញផ្លូវជាតិលេខ៦)*



*សកម្មភាពចុះពិនិត្យស្ថានភាពទឹកជំនន់តាមបណ្ដាស្ទឹងសំខាន់ៗ ជុំវិញបឹងទន្លេសាប (មុខព្រួញផ្លូវជាតិលេខ៥)*

## ខ. ការងារផ្ទៀងផ្ទាត់ទិន្នន័យ និងកំណត់និយាមកា



## គ. ការងារសាងសង់បង្គោលកាត់ផ្ទៀល



## ឃ. ការងារចុះពិនិត្យវាយតម្លៃ និងប្រគល់ទទួលការងារបោះបង្គោលព្រំកាត់ឆៀល



## ង. ការងារអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក



## ច. ការងារចុះសម្របសម្រួលពាក់ព័ន្ធនឹងបញ្ហាក្នុងតំបន់បឹងទន្លេសាប

❖ កិច្ចប្រជុំពិភាក្សាលើសំណើសុំអន្តរាគមន៍ប្រើប្រាស់អាស្រ័យផល និងអភិវឌ្ឍន៍លើផ្ទៃដីទំហំ ៧៧,០៣ហិកតា ស្ថិតក្នុងភូមិសាស្ត្រ (តំបន់២) ភូមិជ្រាវ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប នៅទីស្តីការក្រសួងរៀបចំដែនដី នគររូបនីយកម្ម សំណង់។





❖ កិច្ចប្រជុំពិភាក្សា ស្តីពីការស្នើសុំជួសជុល សាងសង់ និងស្តារប្រឡាយ ទំនប់ អាងទឹក ស្រះ ត្រពាំង នៅតំបន់២ នៃតំបន់បឹងទន្លេសាប ក្នុងភូមិសាស្ត្រខេត្តសៀមរាប។





# ច. ការងារចុះសម្របសម្រួលពាក់ព័ន្ធនឹងបញ្ហាក្នុងតំបន់បឹងទន្លេសាប (ត)

- ដឹកនាំក្រុមការងារអន្តរក្រសួង និងមន្ទីរពាក់ព័ន្ធ ចុះពិនិត្យស្ថានភាពអនាធិបតេយ្យក្នុងតំបន់២ និងតំបន់៣ ដែលស្ថិតនៅតំបន់អភិរក្សបឹងពារាំង និងតំបន់ជុំវិញ រោងចក្រប្រព្រឹត្តកម្មទឹកស្អាតជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។








# ច. ការងារចុះសម្របសម្រួលពាក់ព័ន្ធនឹងបញ្ហាក្នុងតំបន់បឹងទន្លេសាប (ត)

- ប្រតិភូអន្តរក្រសួង ជួបប្រជុំពិភាក្សាបច្ចេកទេសលើរបាយការណ៍បច្ចុប្បន្នភាព ស្តីពីការកំណត់តំបន់ការពារ និងអភិវឌ្ឍន៍ប្រភពទឹកបឹងទន្លេសាប សម្រាប់ផ្គត់ផ្គង់ទឹកស្អាត ក្នុងក្រុងសៀមរាប និងតំបន់ជុំវិញ។






- ការប្រជុំពិនិត្យ និងពិភាក្សាលើសំណើសុំចុះបញ្ជីតំបន់ការពារ និងអភិវឌ្ឍន៍ប្រភពទឹកបឹងទន្លេសាបសម្រាប់ផ្គត់ផ្គង់ទឹកស្អាតខេត្តសៀមរាប។






# ច. ការងារចុះសម្របសម្រួលពាក់ព័ន្ធនឹងបញ្ហាក្នុងតំបន់បឹងទន្លេសាប (ត)

- ចុះពិនិត្យករណីចាក់ដីចូលក្នុងទន្លេសាប ស្ថិតក្នុងភូមិសាស្ត្រភូមិទី១ សង្កាត់ខ្សាម និងភូមិចុងកោះ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។





- ចុះពិនិត្យការជីកស្តារបឹងអភិរក្សរហាលប្រារបស់សហគមន៍នេសាទល្វា នៅក្នុងតំបន់៣ ស្ថិតក្នុងភូមិសាស្ត្រឃុំល្វា ស្រុកពួក ខេត្តសៀមរាប។





# ច. ការងារចុះសម្របសម្រួលពាក់ព័ន្ធនឹងបញ្ហាក្នុងតំបន់បឹងទន្លេសាប(ត)

- ក្រុមការងារបច្ចេកទេសអន្តរក្រសួង និងមន្ទីរធនធានទឹក និងឧតុនិយម ខេត្តសៀមរាប ចុះពិនិត្យស្ថានភាពទីតាំងជាក់ស្តែង ពីដំណើរការជីកកាយស្តាបាតអាងទឹកយកអាចម៍ដី ក្នុងតំបន់២ ស្ថិតក្នុងភូមិសាស្ត្រ សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប។






- ចូលរួមកិច្ចប្រជុំពិនិត្យពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ករណីស្នើសុំគោលការណ៍ស្តារប្រឡាយទឹក ស្ថិតក្នុងភូមិសាស្ត្រឃុំកំពង់ព្រះគគីរ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។





# ច. ការងារចុះសម្របសម្រួលពាក់ព័ន្ធនឹងបញ្ហាក្នុងតំបន់បឹងទន្លេសាប ( ត )

- ចូលរួមកិច្ចប្រជុំជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអាជ្ញាធរដែនដីនៃខេត្តទាំង៦ ជុំវិញបឹងទន្លេសាប ក្នុងការចុះពិនិត្យ ផ្ទៀងផ្ទាត់ទិន្នន័យដីធ្លី តាមបណ្តាឃុំ ស្រុកពាក់ព័ន្ធនឹងតំបន់ទន្លេសាប។



















# ៣.៥ ការវិភាគមុខងារ និងរចនាសម្ព័ន្ធស្ថាប័ន

- ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានចូលរួមកិច្ចប្រជុំលើការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ស្ថាប័ន ផ្ទៃក្នុងអង្គភាព ជាមួយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងមុខងារសាធារណៈ និងក្រុមប្រឹក្សាអ្នកច្បាប់របស់ទីស្ដីការគណៈរដ្ឋមន្ត្រី។
- បានរៀបចំសេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប និងបានឆ្លងក្រុមប្រឹក្សាអ្នកច្បាប់របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអ្នកច្បាប់និងមេធាវីអម ក្រសួងធនធានទឹក និងឧតុនិយម ហើយបានដាក់ជូនក្រសួងមុខងារសាធារណៈ។






# ៤. បញ្ហាប្រឈម

- ធនធានមនុស្ស និងថវិកាមិនទាន់ឆ្លើយតបនឹងទំហំការងារស្នូល និងការងារចំពោះមុខក្នុងការអនុវត្តជាក់ស្តែង
- មធ្យោបាយ សម្ភារសម្រាប់ចុះអនុវត្តការងារ នៅមានការខ្វះខាត
- សម្ភារឧបករណ៍បច្ចេកទេសស្រាវជ្រាវ និងទំនាក់ទំនងព័ត៌មានបែបលក្ខណៈវិទ្យាសាស្ត្រ មិនទាន់ឆ្លើយតប
- កិច្ចសហការ និងចែករំលែកព័ត៌មាន-ទិន្នន័យ ពីបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

# ៥. ដំណោះស្រាយ

- ❑ កសាងសមត្ថភាព និងការយល់ដឹងរបស់មន្ត្រីរដ្ឋបាលសាធារណៈ និងជំនាញបច្ចេកទេស
- ❑ ផ្តល់ការលើកទឹកចិត្តដល់មន្ត្រីបំពេញការងារសកម្ម និងយកចិត្តទុកដាក់គិតគូរពីមន្ត្រីបន្តវេន
- ❑ ពង្រឹងកិច្ចសហការជាមួយក្រសួងស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ❑ សហការជាមួយដៃគូរអភិវឌ្ឍន៍នានា ក្នុងការកៀរគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ

# ៦. ទិសដៅការងារបន្ត

- បន្តតាមដាន និងវាយតម្លៃប្រសិទ្ធភាពអនុវត្តផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ របស់អាជ្ញាធរទន្លេសាប (២០២៤-២០២៨)
- បន្តធ្វើបច្ចុប្បន្នភាព ក្នុងការអនុវត្តសកម្មភាពការងារប្រចាំឆ្នាំ ២០២៦ ឱ្យមានប្រសិទ្ធភាព
- បន្តកិច្ចសហការជាមួយថ្នាក់ដឹកនាំក្នុងអង្គភាព អនុវត្តតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការធ្វើកំណែទម្រង់វិភាគមុខងារ និងរចនាសម្ព័ន្ធថ្មីរបស់អាជ្ញាធរទន្លេសាប ឱ្យមានប្រសិទ្ធភាព
- បន្តស្វះស្វែងកៀរគរជំនួយទាំងបច្ចេកទេស ទាំងថវិកាពីដៃគូនានា
- រៀបចំផែនការដាំស្តារព្រៃលិចទឹកក្នុងតំបន់៣ ដោយសហការជាមួយក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ និងដៃគូនានា
- រៀបចំផែនការសិក្សាពីសក្តានុពលស្ទឹងសំខាន់ៗជុំវិញបឹងទន្លេសាប និងផែនទីស្ថានភាពបាតបឹងទន្លេសាប
- បន្តកសាងសមិទ្ធផលនិងស្នាដៃសំខាន់ៗ ក្នុងការចូលរួមការពារថៃរក្សា ទប់ស្កាត់ការចូលទន្ទ្រានតំបន់ការពារ សំដៅគ្រប់គ្រងតំបន់បឹងទន្លេសាបឱ្យមាននិរន្តរភាព។



# សូមអរគុណ !